ភាគ២ ឆ្នាំ២០២២
ទស្សនៈ អ្នកនិពន្ធ

វ៉ុល៤, លេខ២៨, ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២

# ជ្រុងមួយនៃទិសស្លោកកម្ពុជា «បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីពង្រឹងឯករាជ្យ និងអធិបតេយ្យជាតិ»

ទាន សំណាង* និង រស់ សយម្ហួ**

នៅក្នុងពិភពលោកដែលពោរពេញដោយការប្រកួតប្រជែង ជាពិសេសផ្នែកភូមិសាស្ត្រនយោបាយ វាបានបង្កនូវគ្រោះថ្នាក់យ៉ាងខ្លាំង ដែលទាមទារឱ្យរដ្ឋអំណាចកណ្តាល និងរដ្ឋតូចមានភាពប្រាកដប្រជា និងការប្រុងប្រយ័ត្នខ្ពស់លើសកម្មភាព និងការសម្រេចចិត្តគោលនយោបាយការបរទេសរបស់ខ្លួន។ ការប្រកួតប្រជែងខាងលើ ប្រៀបបាននឹងដើងមេឃដ៏ធំល្វឹងល្វើយ ពុំអាចកំណត់ទីបញ្ចប់បាន រួមជាមួយបញ្ហាប្រឈមប្រពៃណី និងមិនមែនប្រពៃណីផ្សេងទៀត ដូចជា បញ្ហាបម្រែបម្រួលអាកាសធាតុ ជំងឺឆ្លងសាកល ឧក្រិដ្ឋកម្មឆ្លងដែន សន្តិសុខលើលំហអ៊ីនធឺណិត -ល- ដែលកាន់តែបង្កនូវភាពស្មុគស្មាញបន្ថែមទៀតដល់តួអង្គរដ្ឋ។ ថ្វីត្បិតកម្ពុជាជាប្រទេសតូចក៏ពិតមែន ប៉ុន្តែកម្ពុជាមានបេះដូងធំទូលាយ។ ទិសស្លោកកម្ពុជា ***«បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីពង្រឹងឯករាជ្យ និងអធិបតេយ្យជាតិ»*** បានបង្ហាញអំពីធាតុសត្យានុម័តិនៃបំណងកម្ពុជា ជារដ្ឋមួយដែលមិនព្យាយាមបង្កការលំបាក ឬបញ្ហាណាមួយដល់រដ្ឋដទៃនោះឡើយ ពោលគឺស្វែងរកតែកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូតែប៉ុណ្ណោះ ស្របតាមគោលការណ៍សន្តិសហវិជ្ជមាន។ ទោះបីជាមានការគូសបញ្ជាក់ច្បាស់ៗ និងជាក់ស្តែងនៅក្នុងបទដ្ឋានគតិយុត្តិដ៏ចាក់ស្រេះ និងរឹងមាំរបស់ខ្លួនយ៉ាងណាក្តី ក៏កម្ពុជានៅតែទទួលបាននូវការគំរាមកំហែងយ៉ាងកំរោល និងអយុត្តិធម៌ ដោយសារតែកម្តៅនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរបស់ប្រទេសមហាអំណាច។ បញ្ហាសមុទ្ររាម ការចោទប្រកាន់ និងដាក់ការសង្ស័យលើទំនាក់ទំនងរបស់កម្ពុជាជាមួយរដ្ឋដទៃទៀត ពិសេសការចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាស់លាស់ រួមជាមួយបញ្ហាផ្សេងទៀត ធ្វើឱ្យកម្ពុជាមានការងឿងឆ្ងល់ថា តើអ្វីពីកម្ពុជាដែលគេមិនយល់ ឬពុំទាន់យល់ច្បាស់ ឬមួយការមិនយល់នេះ ជាចេតនា?

## រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា

ទិសស្លោក ***«បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីពង្រឹងឯករាជ្យ និងអធិបតេយ្យជាតិ»*** នេះ មានចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៥៣ បានចែងអំពី ការឱ្យតម្លៃប្រទេសទាំងអស់នៅក្នុងសាកលលោក ដោយកម្ពុជាមិនបានចាត់ទុកប្រទេសណាមួយជាសត្រូវ ឬជាទិសដៅ ដើម្បីបង្កជាបញ្ហាជាមួយនោះទេ។ គោលការណ៍សន្តិសហវិជ្ជមានកំណត់ឱ្យកម្ពុជា លើកកម្ពស់ ឱ្យតម្លៃដល់ពហុភាគីនិយម និងបន្តខិតខំពង្រឹងទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយប្រទេសជាមិត្តនានា ដើម្បីរក្សាសន្តិភាព សន្តិសុខ និងវិបុលភាពរួម។ រាល់ការបង្ខិតបង្ខំឱ្យកម្ពុជាជ្រើសរើសមិត្តណាមួយ ឬក៏ទំនាក់ទំនងណាមួយ ដែលនៅស្ថិតក្នុងទម្រង់ជាអនុពហុភាគីនិយម ដែលមានលក្ខណៈប្រឈមមុខ (Conflicting/Confrontational Semi-multilateralism)

---

* **ឯកឧត្តម ទាន សំណាង** គឺជាប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

****លោក រស់ សយម្ហួ** គឺជាអ្នកស្រាវជ្រាវជំបូងនៃសមាគមសាលាត្រាជូ។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

គឺហាក់ដូចជាជំរុញឱ្យកម្ពុជា ប្រាសចាកនូវកាតព្វកិច្ចរបស់ខ្លួន ដូចដែលមានចែងក្នុងមាត្រាដដែល ត្រង់នយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ប្រសិនបើកម្ពុជាធ្វើដូចអ្វីដែលគេបានដាក់សម្ពាធនោះ។ ដូច្នេះ អនុលោមតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញ កម្ពុជានៅតែបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវពហុភាគីនិយម ដែលមានលក្ខណៈឯកភាពសហប្រតិបត្តិការ និងសន្តិសហវិជ្ជមាន។

## ធម្មនុញ្ញអាស៊ាន

និន្នាការ និងកាតព្វកិច្ចក្នុងការស្តារឡើងវិញនូវទំនាក់ទំនងសហប្រតិបត្តិការ ឬការរក្សាពង្រឹងមិត្តភាពជាមួយមិត្តចាស់ និងស្វែងរកការពង្រីកទំនាក់ទំនងជាមួយមិត្តថ្មី (រក្សាចាស់ បង្កើតថ្មី) របស់កម្ពុជា មិនមែនជាគោលការណ៍ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាតែមួយគត់នោះទេ។ ជាក់ស្តែង ធម្មនុញ្ញអាស៊ានត្រង់មាត្រា១ វាក្យខណ្ឌ១ ក៏បានចែងអំពីគោលការណ៍សន្តិភាពនិយម សម្រាប់បណ្តារដ្ឋជាសមាជិកផងដែរ។ ត្រង់ចំណុចនេះ ប្រសិនបើមានការតម្រូវ ឬចាប់បង្ខំទំនាក់ទំនងសហប្រតិបត្តិការជិតស្និទ្ធ ឬជ្រើសរើសប្រទេស ឬក្រុមប្រទេសណាមួយជាមិត្ត ក្នុងគោលបំណងជល់គ្នា ជាមួយក្រុមប្រទេសណាមួយផ្សេងទៀតនោះ គោលការណ៍សន្តិភាពនិយម ហាក់បីដូចជាចំណាប់ខ្មាំង នៃអនុពហុភាគីនិយម ដែលមិនបានគាំទ្រដល់ពហុភាគីនិយមដើម្បីកំណើនរួមនោះទេ។ ខ្លឹមសារត្រង់នេះ នៅមិនទាន់បានរាប់បញ្ចូលកាតព្វកិច្ចទូទៅមិនចំពោះដទៃទៀត ដូចជាមាត្រា១ វាក្យខណ្ឌ៤ និង ១៥ និងមាត្រា ២ វាក្យខណ្ឌ ២ ទេ។ កាន់តែពិសេសទៅទៀតនោះ ធម្មនុញ្ញអាស៊ាន មិនបានកំណត់ ឬហាមឃាត់ រដ្ឋជាសមាជិកក្នុងការធ្វើទំនាក់ទំនង ជាមួយក្រុមប្រទេសណាមួយឡើយ ហើយកាន់តែមិនបានចាប់បង្ខំរដ្ឋជាសមាជិកណាមួយ ធ្វើការជ្រើសរើសមិត្តរបស់ខ្លួនផងដែរ។ ក្នុងន័យនេះ មិនមែនមានន័យថា រដ្ឋជាសមាជិក ត្រូវបោះបង់ឯករាជ្យ និងអធិបតេយ្យរបស់ខ្លួននោះទេ ហើយជាពិសេស កម្ពុជាក៏ត្រូវការការពារឯករាជ្យ និងអធិបតេយ្យរបស់ខ្លួនផងដែរ។ អ្វីដែលសំខាន់នោះ កម្ពុជាក្នុងក្របខ័ណ្ឌជាតិក្តី អាស៊ានក្តី គឺមិនអាចធ្វើដើម្បីតម្រូវចិត្តរដ្ឋណាមួយ ដែលអាចធ្វើឱ្យខូចប្រយោជន៍ជាតិ និងប្រជាជនរបស់ខ្លួនបានឡើយ។ ដូច្នេះ រាល់ទំនាក់ទំនងណាដែលមានប្រយោជន៍សម្រាប់ជាតិ និងប្រជាជនកម្ពុជា ក្នុងការពង្រឹងឯករាជ្យ និងអធិបតេយ្យ ជាពិសេស ចូលរួមដល់កំណើនរួម គឺមិនគួរចាត់ទុកជាបញ្ហានោះទេ។

ម្យ៉ាងវិញទៀត សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation [TAC]) មាត្រា១ បានចែងអំពីការលើកកម្ពស់សុខដុមនីយកម្ម និងសន្តិភាព ខណៈដែលមាត្រា២ (ច) បានចែងអំពីកិច្ចសហប្រតិបត្តិការដែលមានប្រសិទ្ធភាពរវាងរដ្ឋជាសមាជិក។ អ្វីដែលសំខាន់នោះ ជំពូក២ និង ជំពូក៣ នៃសន្ធិសញ្ញាខាងលើ បានផ្តល់នូវការណែនាំយ៉ាងច្បាស់ ក៏ដូចជាកាតព្វកិច្ចចាំបាច់របស់រដ្ឋសមាជិក ក្នុងការពង្រឹង និងពង្រីកមិត្តភាពប្រកបដោយសុចរិតភាព ដោយមិនប្រកាន់ និងមិនចំពោះប្រទេស ឬក្រុមប្រទេសណាមួយឡើយ ក្នុងការចូលរួមចំណែកពង្រឹងសុខសន្តិភាព និងកំណើនរួម។

ដូច្នេះ អនុលោមតាមបទដ្ឋានគតិយុត្តតំបន់ កម្ពុជាមានការចាំបាច់គោរពនូវកាតព្វកិច្ចនេះ ពិសេស ការរក្សា និងបង្កើនកិច្ចសហប្រតិបត្តិការ។ បទដ្ឋានគតិយុត្តតំបន់ ក៏មិនបានហាមប្រាមកម្ពុជា ក៏ដូចជាប្រទេសក្នុងតំបន់ មិនឱ្យប្រាស្រ័យទាក់ទងក្រុមប្រទេសណាមួយនោះដែរ។ ចំណុចដែលសំខាន់នោះ គឺសុខដុមនីយកម្ម សន្តិភាព និងកំណើនរួម សម្រាប់ជាប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា និយាយដោយឡែក និងតំបន់ និយាយជារួម។

## ធម្មនុញ្ញអង្គការសហប្រជាជាតិ

ការពង្រឹង និងពង្រីកសហប្រតិបត្តិការ ដោយយកការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច និងសង្គមជាគោល គឺមានសារៈសំខាន់ណាស់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

មាត្រា១ វាក្យខណ្ឌ២ និង វាក្យខណ្ឌ៤ បានចែងយ៉ាងច្បាស់អំពីការអភិវឌ្ឍ និងបង្កើតនូវចំណងជាមិត្តភាព របស់ប្រទេស

ជាសមាជិក ដោយស្មើភាព ស្មើសិទ្ធិ ប្រកបដោយសាមគ្គីភាពជាធ្លុងមួយ។ អ្វីដែលសំខាន់នោះ គឺការរក្សានូវសន្តិភាព និងសន្តិសុខពិភពលោក ចែងនៅក្នុងមាត្រា១ វាក្យខណ្ឌ១ ជាកាតព្វកិច្ចចម្បងមួយសម្រាប់ប្រទេសជាសមាជិក។ ក្នុងន័យនេះ តើការបែងចែកបក្ខពួកក្រុមប្រទេស ការបង្ខំឱ្យជ្រើសរើសមិត្ត ឬចំណងមិត្តភាព ការធ្វើនយោបាយនីយកម្មនានា ដើម្បីបង្ខិតបង្ខំ កាត់ផ្ដាច់ ឬបង្កើតចំណងមិត្តភាពវិសមភាពណាមួយជាដើម នឹងបង្កឱ្យពិភពលោកយើងនេះ ទទួលបាននូវសន្តិភាព និងសន្តិសុខដែរឬទេ? ធម្មនុញ្ញអង្គការសហប្រជាជាតិ ហាក់ដូចជាមិនបានបង្អាក់ដំណើរនៃសាកលភាវូបនីយកម្ម និងសមាហរណកម្មរបស់ពិភពលោកនោះទេ។ ជាក់ស្ដែង ធម្មនុញ្ញអង្គការសហប្រជាជាតិ មិនបានហាមឃាត់រដ្ឋណាមួយធ្វើទំនាក់ទំនងគ្នានោះទេ ផ្ទុយទៅវិញមានតែបង្ហាញពីការជំរុញ និងពង្រឹងសាមគ្គីភាព ដោយស្មើភាព និងស្មើសិទ្ធិក្នុងការធ្វើទំនាក់ទំនងរវាងរដ្ឋ។ ពិសេសធម្មនុញ្ញអង្គការសហប្រជាជាតិក៏បានបង្ហាញពីយន្តការដទៃទៀតដូចជា យន្តការតំបន់ដែលចូលរួមលើកកម្ពស់គោលបំណងចម្បង នៅក្នុងការថែរក្សាសន្តិភាព និងសន្តិសុខពិភពលោក។ យន្តការតំបន់អាចមានច្រើន និងចម្រុះ ហើយក៏ជាផ្នែកមួយដែលបង្ហាញពីពិពិធភាពសាកលលោកផងដែរ។ ដោយឡែក ការពង្រឹងសាមគ្គីភាព ដោយស្មើភាព និងស្មើសិទ្ធិក្នុងការធ្វើទំនាក់ទំនងរវាងរដ្ឋ គឺជាផ្នែកមួយនៃដំណើរសាកលភាវូបនីយកម្មដ៏ចាក់ស្រេះ ពិសេសដើម្បីជាចំណែកដល់ការថែរក្សាសន្តិភាព និងសន្តិសុខពិភព-លោក ក្នុងនោះធម្មនុញ្ញអង្គការសហប្រជាជាតិក៏ជាកត្តាមួយជំរុញនូវការអនុវត្តយន្តការទីផ្សារសេរីនិយមផងដែរ។

សរុបសេចក្ដីមក ការចោទប្រកាន់ និងដាក់ការសង្ស័យលើទំនាក់ទំនងរបស់កម្ពុជា ជាមួយរដ្ឋដទៃទៀត ពិសេសការចោទប្រកាន់ដែលមិនមានមូលដ្ឋានច្បាស់លាស់ និងការបង្ខំឱ្យកម្ពុជាជ្រើសរើស ឬផ្ដល់តម្លៃលើកិច្ចសហប្រតិបត្តិការជាមួយមិត្តណាមួយនោះ ហាក់បីដូចកំពុងបង្ខំឱ្យកម្ពុជា រំលោភច្បាប់ជាធរមាន ដែលមិនត្រឹមតែរំលោភលើច្បាប់កំពូលរបស់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចមានព្យសនកម្មដល់កាតព្វកិច្ចតំបន់ និងពិភពលោកថែមទៀត។ ការបង្ខំកម្ពុជាម្ដងហើយម្ដងទៀត អាចនឹងបង្ហាញចម្លើយឱ្យឃើញយ៉ាងច្បាស់ថា នោះគឺជាចេតនា ទាមទារតែផលប្រយោជន៍សម្រាប់ប្រទេសរបស់ខ្លួនប៉ុណ្ណោះ ដោយមិនបានខ្វាយខ្វល់ពីបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិនានា ដែលកំពុងស្ថិតនៅជាធរមាននោះទេ។ ទិដ្ឋភាពនេះ ប្រសិនបើប្រព្រឹត្តដោយប្រទេសមានឥទ្ធិពល ហើយថែមទាំងជាក្បាលម៉ាស៊ីនបង្កើតច្បាប់អន្តរជាតិផងនោះ អាចបង្កជាការព្រួយបារម្ភខ្លាំងចំពោះគោលការណ៍នីតិរដ្ឋ។ ប្រសិនបើដូច្នេះមែន ប្រទេសតូចនៅតែគេចមិនផុតពីស្រមោលអាណានិគមនោះទេ។ ដោយឡែកទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ បានគូសបញ្ជាក់ថា កម្ពុជាជាប្រទេសតូចពិតមែន ប៉ុន្តែអាច **បង្កើនមិត្តខាងក្រៅបាន។ កម្ពុជា មានអធិបតេយ្យ និងសិទ្ធិពេញលេញ ក្នុងការធ្វើទំនាក់ទំនង និងជាដៃគូសហប្រតិបត្តិការនានា នៅក្នុងរង្វង់ការការពារដោយច្បាប់ ដើម្បីជាប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា។**

អត្ថបទនេះសូមបញ្ចប់ដោយសុភាសិត *«ពុតត្រូកុំត្រាប់ ច្បាប់ត្រូ ឱ្យយក»* ដោយសូមឱ្យអ្នកអានត្រិះរិះពិចារណាតាមការគួរ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center